

# ព្រះមហា ឡុង-ឌិ តន្តប្បញ្ញោ

អាចារ្យបង្រៀននៅសាលាបាលីរង

វត្តសារាវ័ន តេជោ-ភ្នំពេញ

រៀបរៀង

ព.ស ២៤៩៤

គ.ស ១៩៤២

បាតុចិបសតំធម្មោ ធម្មាធពោចបុគ្គលា

ផ្សាយចេញពី

# www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality



ព្រះគ្រូធម្មសារមុនី

លេខកូដ :
លេខរៀង :

នៃព្រះគ្រូធម្មសារមុនី លុក-យូរ ហៅ ណាគោ អនុគណព្រះគ្រូធម្ម-សារមុនី បិតា នាម លុក មាតា នាម ហែម កើតនៅថ្ងៃព្រហស្បតិ៍ ៤ កើត ខែមិគសិរ ឆ្នាំកុរឯកស័ក ព្រះជន្ម ៤៣ ឆ្នាំ ព.ស. ២៤៤១ ក្នុងភូមិគាំងឫស្សី ឃុំពត់សរ ស្រុកបាទី ខេត្តតាកែវ, កាលអាយុ ៨ ឆ្នាំ បានសិក្សាអក្សរសាស្ត្រនៅផ្ទះនឹងអាចារ្យ ឡុច ជាម៉ា ដរាបដល់មើលអក្សរបានខ្លះៗ ដល់អាយុ ៩ ឆ្នាំ មាតាបិតាក៏នាំកុមារ លុក-យូរ ឲ្យទៅនៅវត្ត បឹកប៉ិតមាស ឃុំ-ស្រុក-ខេត្តជាមួយគ្នា ដើម្បីសិក្សាអក្សរថែមទៀត ក្នុងសំណាក់លោកគ្រូព្រះបាឡាត់គណព្រះនាម សោម ជាចៅអធិការ ។ កុមារ លុក-យូរ បានយកចិត្តទុកដាក់ក្នុងការរៀនសូត្រ និងមិនមួយម៉ាត់ៗ ឥតធ្វេស ។

ដល់អាយុ ១៣ ឆ្នាំ ក៏រៀនចេះដឹងអក្សរនិងនព្វន្តតាមសម័យនិយម ជាអ្នកឈ្លាសវៃជាងកុមារស្រករគ្នា លោកគ្រូសព្វព្រះទ័យជាងកុមារឯទៀត ព្រោះឃើញចរិយាល្អ លោកក៏ទូន្មានធម្មទៅ លុះធ្វើឈាបនកិច្ចហើយ ត្រឡប់ទៅផ្ទះដើម្បីបម្រើមាតាបិតា ដល់អាយុ ១៧ ឆ្នាំ មាតា-បិតានាំកុមារ លុក-យូរ មកបួសជាសាមណេរ នៅវត្តបឹកប៉ិតមាសដដែល បានលោកគ្រូព្រាប-ឌូច ចៅអធិការជាឧបជ្ឈាយ៍ ។ កុមារ លុក-យូរ បព្វជ្ជាជាសាមណេរ នៅខែវិសាខ ឆ្នាំថោះសប្តស័ក ព.ស. ២៤៥៨ ដល់អាយុ ១៩ ឆ្នាំ ក៏លាចាកសិក្ខាបទពីសាមណេរ ។ ក្រោយ

២០ ឆ្នាំ បណ្ឌិតលុក-យូរ បានមកបួសជាសាមណេរមួយព្រាំងទៀត អាយុគ្រប់ ២១ ឆ្នាំ ក៏ឧបសម្បទជាភិក្ខុភាវក្នុងពុទ្ធសីមាវត្តបឹងបក់បិតមាសដដែល បាននាមឆាយាជា សុវណ្ណកេរ្តិ៍ នៅថ្ងៃសុក្រ ៣ កើតខែវិសាខ ឆ្នាំមមែសំរឹទ្ធិស័ក ព.ស. ២៤៦២

បាននិមន្តព្រះគ្រូមុនីសំវរបញ្ញា នាម (អ៊ុក) វត្តបឹងឡាងឃុំបឹងឡាង ស្រុកកណ្ដាលស្ទឹង (កណ្ដាល) ជាឧបជ្ឈាយ៍ ព្រះព្រហ្មសរ នាម (ព្រាប-ខូច) ជាកម្មវាចាចារ្យ, ព្រះកេសរកេរ្តិ៍ នាម គាំ-ច្រះកា ជាអនុសាវនាចារ្យ, ភិក្ខុ លុក-យូរ នៅក្នុងវត្តដដែល បានរៀនវិបស្សនាកម្មដ្ឋាន ក្នុងសំណាក់លោកគ្រូអាចារ្យ ឈុន ហើយរៀននឹងលោកគ្រូអាចារ្យ ពេជ្រ (ជាឧបាសក) ថែមទៀត បានលួមពត់ចិត្តធ្វើចិត្ត ចំនួន ៤ វស្សា លុះដល់វស្សាទី ៣ ក៏ផ្លាស់ការសិក្សាវិបស្សនាកម្មដ្ឋានទៅ បានរៀនមើលគម្ពីរជាច្រើន បានទន្ទេញបាលីភិក្ខុបាដិមោក្ខចាំមាត់រទេះដែងកើត និងបានជួយកសាងព្រះវិហារ, កុដិ, សាលា ។

លុះបព្វជ្ជាបាន ៧ វស្សា ឆ្នាំខាលអដ្ឋស័ក ព.ស. ២៤៦៨ ព្រះវិសុទ្ធិវង្សាបាឡាត់គណ នាម (សំ-ប៊ុត) ចៅអធិការវត្តទន្លេបាទី ឃុំត្រាំងធ្នង់ ស្រុកបាទី (តាកែវ) បានទៅសុំភិក្ខុ លុក-យូរ អំពីលោកគ្រូ ព្រាប-ខូច ជាចៅអធិការឲ្យមកនៅវត្តទន្លេបាទី មកដល់ហើយបានភិក្ខុ-សាមណេរឲ្យថែរាំ ជំនួសលោក ជួយបង្ហាត់បង្រៀនធម៌អាថ៌ភាសាទេពត្ពន្ធជាដើម ដល់ឆ្នាំរោង

សំរិទ្ធិស័ក ព.ស. ២៤៧១ តាំងជាគ្រូសូត្រស្តាំសម្រាប់វត្តទន្លេបាទី, បាន
ធ្វើគ្រូបង្រៀនសាលាបឋមវិជ្ជា បាន ២ ឆ្នាំ, ដល់ឆ្នាំកុរសប្តស័ក ព.ស.
២៤៧៨ ព្រះវិសុទ្ធិវង្សាបាឡាត់គណលាចាកសិក្ខាបទ បានតាំងលោកគ្រូ
សូត្រ លុក-យូរ ជាចៅអធិការជំនួសមក ដល់ឆ្នាំជូតអដ្ឋស័ក ព.ស.
២៤៧៩ [illegible]ទីដថ្ងៃ (២៧ វិច្ឆិកា គ.ស. ១៩៣៦) បានស្តីទីជាបាឡាត់គណ
ស្រុកបាទីជួសលោកគ្រូ (សំ-ប៊ុត) បានកសាងព្រះវិហារ, សាលា, កុដិ,
បង្គន់ ។ល។ ដល់ឆ្នាំវកឯស័ក ថ្ងៃទី ២០ មិថុនា ព.ស. ២៤៨៧ គ.ស.-
១៩៤៤ ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន គឺព្រះករុណាជាម្ចាស់
ជីវិតលើត្បូងសព្វថ្ងៃ ព្រះរាជទានគ្រឿងឥស្សរិយយស សីវីលីយ៉ោស្បុន
ដូណេរ៏ ឈ្មោះអស្សរិទ្ធិ (មេដាយប្រាក់) ដល់ឆ្នាំរោងទោស័ក ព.ស.
២៤៨៣ ថ្ងៃទី ៩ (កញ្ញា) ឆ្នាំ ១៩៤០ កាលនោះ សម្តេចព្រះមហាសុមេ-
ធាធិបតី ព្រះនាម ប្រាក់-ហ៊ិន នៅស្តីទីសង្ឃនាយកគណៈមហានិកាយ បាន
តាំងជាព្រះវិសុទ្ធិវង្សាបាឡាត់គណសម្រាប់ស្រុកបាទី (តាកែវ) ។

បន្ទាប់មកបានឡើងជាព្រះគ្រូធម្មសរមុនីអនុគណ ស្រុកបាទី (តាកែវ)
ដោយមានសញ្ញាប័ត្រលេខ ៩៧១ ចុះថ្ងៃ ៦ ១ ៨ ឆ្នាំខាលទោស័ក ព.ស.
២៤៩៣ នៃសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក ព្រះនាម ជ.ណ. ។

# អារម្ភកថា

ហេតុដែលកើតសៀវភៅ "បាថេយ្យកថា និង កាសិតោវាទ" នេះឡើង ដោយពួកសិស្សានុសិស្សព្រមទាំងបរិស័ទជើងវត្ត ត្រូវការធ្វើបុណ្យចំរើនព្រះជន្មវស្សា ព្រះតេជព្រះគុណ ព្រះគ្រូធម្មសរម៉ុនី អនុគណ វត្តទន្លេបាទី ឃុំក្រាំងធ្នង់ស្រុកបាទី (តាកែវ) ។

នៅថ្ងៃសៅរ៍ ១១ កើតខែចេត្រឆ្នាំថោះត្រីស័ក ព.ស. ២៤៩៤ ត្រូវនឹងថ្ងៃទី ៥ មេសាឆ្នាំ ១៩៥២ បង្ហើយដល់ថ្ងៃចន្ទ ១៣ កើត ខែ ឆ្នាំដដែល ជួបជុំព្រះសង្ឃពុទ្ធបរិស័ទជាច្រើន ក៏ក្នុងពិធីបុណ្យនេះ គួរឲ្យមានសៀវភៅធម៌អ្វីមួយចែកផ្សាយជាធម្មទាន ព្រោះជាទានប្រសើរបំផុត ។

ពួកសិស្សានុសិស្សទាំងអស់ បានមកនិមន្តខ្ញុំឲ្យរៀបរៀងធម៌អ្វីមួយ បោះពុម្ពផ្សាយក្នុងបុណ្យនេះ សេចក្តីនិមន្តក៏ត្រូវចំលើគំនិតខ្ញុំគិតមកយូរហើយដែរ ខ្ញុំបានដកយក បាថេយ្យសូត្រ ក្នុងសុត្តន្តបិដកសំយុត្តនិកាយ សគាថវគ្គ ទេវតាសំយុត្ត, ដោយសេចក្តីក្នុងសូត្រមានចំនួនតិចពេក ខ្ញុំបានបន្ថែមធម៌ច្រើនមកទៀត ដូចប្រាប់គម្ពីរសព្វគ្រប់ស្រាប់ ហើយឈ្មោះជា "បាថេយ្យកថា" ឲ្យជាការងាយដល់អ្នកមើល-ស្តាប់ខាងដើម, យកកាសិតោវាទនឹងគិរប្រាប់ថ្ងៃ-ខែ-អតីត-បច្ចុប្បន្ន-អនាគត ជាខាងចុង បានជាដាក់គំរូនេះមក ដោយមានភិក្ខុជាច្រើនរូប និយាយថា គួរតែដាក់ឲ្យមានជាបែបតទៅ

ព្រោះបព្វជិតដែលបួសថ្មី ៗ ដោយមិនបានរៀនសូត្រហ្មត់ចត់ មិនយល់វិធី
ប្រាប់សកកាជ ថៃ-ខែ ដោយងាយបាន ក្នុងវត្តមួយ ៗ ច្រើនចេះតែលោក
ចាស់ ៗ ការរាក់មកនេះមិនមែនសព្វគ្រប់អស់បំណាច់ក្នុងវែបនេះដែរ
ព្រោះកុំឲ្យចំពីរសៀវភៅការតែច្រើនហួស តែងាយជាងគ្មានសោះ ។

កាល[redacted]បរៀនរួចហើយ បានយកទៅប្រគេនព្រះតេជព្រះគុណ
ព្រះវិន័យសំវរ ថ.-គីង សាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ ហើយយកទៅ
ប្រគេនព្រះតេជព្រះគុណព្រះពោធិវង្ស ហ.-តាត ចាងហ្វាងសាលាបាលី
ជាន់ខ្ពស់ពិនិត្យកែម្តងទៀតហើយយល់ថា គួរដល់ការបោះពុម្ពបាន ។
សូមលោកអ្នកប្រាជ្ញទាំងឡាយ បើឃើញខុសឆ្គាំឆ្គងត្រង់កន្លែងណា
ជួយកែតម្រូវឲ្យបានផង ។ សូមអរព្រះគុណយ៉ាងក្រៃលែង ចំពោះព្រះ
តេជព្រះគុណព្រះពោធិវង្ស និងព្រះតេជព្រះគុណព្រះវិន័យសំវរ ជួយពិ
និត្យកែដោយសេចក្តីអនុគ្រោះ ក្នុងការធ្វើសៀវភៅនេះ បានកិច្ចមហាបរិយត្តិ
សេង-គឹមស្រេង សិស្សសាលាបាលីជាន់ខ្ពស់ សរសេរចម្លងពីសំណៅ,
ព្រះគ្រូវិនយបញ្ញា យី-លៀង វត្តសារាវ័នជួយត្រួតសំរួលទៀត ដរាបដល់
ចេញការពុម្ព ។

យើងខ្ញុំទាំងឡាយ បានធ្វើធម្មទាន ដ៏អាមិសទានក្នុងពេលបុណ្យចំ
រើនព្រះជន្មទាំងប៉ុន្មាន សូមប្រគេន-ជូនកុសលនេះ ចំពោះលោកអ្នកមាន

គុណទាំងឡាយ មានព្រះគ្រូធម្មសរមុនី នឹងមាតាបិតាជាដើម រស់នៅសព្វថ្ងៃក្ដី ស្លាប់ហើយក្ដី ព្រមទាំងអ្នករៀន-ស្ដាប់ធម៌នេះក្ដី សូមឧត្តមផលនេះ តាមសណ្ឋិតកងជូនវិញ្ញាណលោកអ្នកមានគុណទាំងនោះ ឲ្យជួបប្រទះតែនឹងមហន្តផល គឺសេចក្ដីសុខ-ចំរើនដរាបដល់ព្រះនិព្វានកុំបីខាន សូមព្រះពុទ្ធសាសនារុងរឿងគ្រប់៥០០០ព្រះវស្សា កុំបីឃ្លៀងឃ្លាតឡើយ

លុះខ្ញុំរៀបរៀងហើយ មានព្រះសង្ឃជាច្រើន ត្រូវការធ្វើបុណ្យទក្ខិណានុប្បទានរៀងរាល់កន្លែង បានជួយចេញថ្លៃពេងពុម្ព យកសៀវភៅនេះផ្សាយជាធម្មទាន គឺ :

១— លោកគ្រូ ជូ-ផេង បាងហ្វាងសាលាបឋមវិជ្ជា វត្តសាំផ្សាមី ឃុំកំពង់លាវ ស្រុកព្រៃវែង (ព្រៃវែង)

២— ភិក្ខុ មហាឧត្តមវិជ្ជា វ៉ិត-ដរ វត្តសារាវ័ន សង្កាត់លេខ ៣ ភ្នំពេញ

៣— មហាបរិយត្តិ តាត់-អ៊ី អាចារ្យបង្រៀនសាលាបាលីរង់វត្តជីរោ ឃុំជីរោ ស្រុកត្បូងឃ្មុំ (កំពង់ចាម)

៤— អាចារ្យ សៅ-ជូ អាចារ្យបង្រៀនសាលាបាលីរង វត្តពោធិ-ហាន់ជ័យ ឃុំឆ្លូង ស្រុកឆ្លូង (ក្រចេះ)

៤— លោកគ្រូបង្រៀនសាលាបឋមវិជ្ជា ម៉ម-យុត វត្តខ្ទម ឃុំកំពង់ទ្រាំង ស្រុករលាប្អៀរ (កំពង់ឆ្នាំង) ។

៥— មហា ចាប់-អ៊ូ វត្តសារាវ័ន សង្កាត់លេខ ៣ ភ្នំពេញ

វត្តសារាវ័ន ក្រុងភ្នំពេញ

នៅថ្ងៃ ៤ ៗ ១៤ ១២ ឆ្នាំថោះត្រីស័ក ព.ស. ២៤៩៤

ត្រូវនឹងថ្ងៃទី ២៨ វិច្ឆិកា គ.ស. ១៩៥១

ព្រះមហា ឡុង-ឆុន (ឥន្ទបញ្ញោ)

×+×

# នមក្ការគាថា

នមាមិ ពុទ្ធំ វរទក្ខិណេយ្យំ
នមាមិ ធម្មំ សុគតេន វុត្តំ
នមាមិ សង្ឃំ អរិយំសុខេត្តំ
តស្សានុភាវេន សុខី សិរី សទា

ខ្ញុំព្រះករុណាសូមនមស្ការ ចំពោះព្រះពុទ្ធ ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ, សូមនមស្ការ ចំពោះព្រះសទ្ធម្មជាធម៌ គឺព្រះសុគតសំដែង ហើយដោយប្រពៃ; សូមនមស្ការ ចំពោះព្រះអរិយសង្ឃជាស្រែបុណ្យដ៏ល្អ ។

ដោយអានុភាពនៃកិរិយានមស្ការចំពោះព្រះត្រ័យរតន៍នោះ សូមឲ្យសេចក្ដីសុខចំរើនសិរីសួស្ដី កើតមានសព្វ ។ កាល ។

គាថានេះនឹងពណ៌នាសេចក្ដី ក្នុងបាថេយ្យគាថា ដែលទេវតាទូលសួរព្រះអរហំសម្ពុទ្ធ ហើយព្រះអង្គដោះទូលសេចក្ដីសង្ស័យនៃទេវតា ដូចមានក្នុងសុត្តន្តបិដកសំយុត្តនិកាយ ។

ទេវតាសួរព្រះសម្ពុទ្ធជាម្ចាស់ថា:

កឹសុ ពន្ធតិ បាថេយ្យំ
កឹសុ ភោគានមាសយោ

កឹសុ នរំ បរិកស្សតិ
កឹសុ លោកស្មិ ទុជ្ឈហំ
កឹសុ ពទ្ធា បមុច្ចិ សត្តា
បាសេន សកុណី យថាតិ ។

ប្រែថា: អ្វីរមែងចងទុកនូវសេចក្ដីកុសល
អ្វីជាទីនៅអាស្រ័យនៃគោត:ពាំងឡាយ
អ្វីរមែងកើតក្រោកនរជនយកទៅ
អ្វីដែលបុគ្គលលះបង់បានដោយកម្រក្នុងលោក
សត្វមានកិលេសក្រាស់ជាប់ជំពាក់នៅក្នុងរបស់អ្វី
ដែលដូចជាមេបក្សីជាប់អន្ទាក់ ។

ព្រះសម្មុទ្ធជាម្ចាស់ត្រាស់ថា:

សទ្ធា ពន្ធតិ បាថេយ្យំ
សិរី ភោគានមាសយោ
ឥច្ឆា នរំ បរិកស្សតិ
ឥច្ឆា លោកស្មិ ទុជ្ជហា
ឥច្ឆា ពទ្ធា បុថុ សត្តា

## ៤. បាសេន សកុណាំ យថា ។

ប្រែថា : សទ្ធារមែងចងទុកនូវស្បៀងគឺកុសល
សិរីជាទីនៅអាស្រ័យនៃភោគៈទាំងឡាយ
សេចក្តីប្រាថ្នារមែងកើតកន្ត្រាក់នរជនទៅ
សេចក្តីប្រាថ្នាក្រមបុគ្គលលះបង់បានក្នុងលោក
សត្វមានកិលេសក្រាស់រមែងជាប់នៅសេចក្តីប្រាថ្នា ដូចជាមេ
បក្សីជាប់អន្ទាក់ ។

## សេចក្តីអធិប្បាយ

សាសនសុភាសិតដែលសម្តេចព្រះអរហំសម្មាសម្ពុទ្ធជាគ្រូធំទ្រង់ដោះស្រាយបញ្ហាដែលទេព្តទូលសួរព្រះអង្គ ដូចនិពន្ធគាថា ខាងលើនេះ នឹងញែកចេញជា៤បទគឺៈ សទ្ធា ពន្ធតិ បាថេយ្យំ មួយបទ,សិរី ភោគានមាសយោ មួយបទ, ឥច្ឆានរំ បរិកស្សតិ មួយបទ,ឥច្ឆាលោកស្មិំ ទុជ្ជហា មួយបទឥច្ឆា ពទ្ធា បុថុ សត្តា បាសេន សកុណី យថា មួយបទ បន្ទាប់អំពីនេះទៅនឹងសូមដកស្រង់យកពុទ្ធភាសិត មួយបទម្តងៗ មកអធិប្បាយចែកជូនពុទ្ធមាមកជន ដូចតទៅនេះ

១)–សទ្ធា ពន្ធតិ បាថេយ្យំ សទ្ធារមែងចងទុកនៅស្បៀងគឺកុសល, សួរថាហេតុអ្វី ក៏បានជាព្រះអនាវរញ្ញាណ ទ្រង់សំដែងថាសទ្ធាជាធម្មជាតិ

អាចចងទុកនូវស្បៀងគឺកុសល? ឆ្លើយថា សទ្ធានេះ បានជាព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់សំដែងថាជាធម្មជាតិ អាចចងទុកនូវស្បៀងគឺកុសល ដូច្នេះព្រោះថាសទ្ធានេះ បើមាននៅក្នុងសន្ដានរបស់បុគ្គលណាហើយ បុគ្គលនោះឯងឈ្មោះថាជាអ្នកមានស្បៀងគឺកុសល សម្រាប់ជួយជូនដំណើរទៅក្នុងលោកខាងមុខ សមដូចជាពុទ្ធសាសនសុភាសិត ដែលព្រះអនាវរណញ្ញាណ ទ្រង់ត្រាស់ទុកក្នុងទេវតាសំយុត្ត ថា:សទ្ធាយំ ធរតិ ន្ទឃំ សត្វលោកអាចទ្រទ្រង់នូវទ្រព្យបានដោយសារសទ្ធា, សទ្ធា សគ្គស្ស សោបាណំ សទ្ធាជាជណ្ដើរ សម្រាប់ឡើងទៅកាន់ស្ថានសួគ៌, សុខា សទ្ធា បតិដ្ឋិតា សទ្ធានេះបើមាននៅក្នុងសន្ដានអ្នកណាហើយ អាចនាំសេចក្ដីសុខមកប្រគល់ឲ្យអ្នកនោះជាមិនខាននឡើយ សទ្ធា ទុតិយា បុរិសស្ស ហោតិ សទ្ធាជាទី ២ គឺជាគូគារបស់បុរស សទ្ធា សាធុ បតិដ្ឋិតា សទ្ធាដែលបុគ្គលដំកល់ស៊ប់ ហើយអាចនាំផលប្រយោជន៍ឲ្យសម្រេចបាន សទ្ធីធ វិត្តំ បុរិសស្សសេដ្ឋំ សទ្ធាជាទ្រព្យឲ្យសុខដ៏ប្រសើររបស់បុរសក្នុងលោកនេះ ។

២)– សិរី ភោគានមាសយោ សិរីជាទីលំនៅអាស្រ័យនៃភោគៈទាំងឡាយ, សួរថាហេតុអ្វីបានជាព្រះដ៏មានជោគទ្រង់ត្រាស់ថា

សិរីជាទីលំនៅអាស្រ័យនៃភោគៈទាំងឡាយ? ឆ្លើយថា សិរីនេះបានជាព្រះដ៏មានជោគទ្រង់ត្រាស់ថា ជាទីនៅអាស្រ័យនៃភោគៈទាំងឡាយដូច្នេះ ព្រោះពាក្យថា សិរីនេះជាឈ្មោះនៃសភាវធម៌ដែលមនុស្ស, ទេវតា, យមយក្ស, ឥន្ទ្រ, ព្រហ្មជាដើម គេត្រូវការប្រាថ្នាចង់បានគ្រប់ៗ ប្រាណទាំងអស់; ឯសិរីបើស្ថិតនៅក្នុងសន្តានៃបុគ្គលណាហើយ រមែងស្ទួយយកយោងបុគ្គលនោះឲ្យចូលទៅកាន់ភាពដ៏ធំយ៉ាងក្រៃលែង មានភាពជាអ្នកមានសម្បត្តិច្រើន ឬ ក៏ជានាហ្មឺនសព្វមុខមន្ត្រីជាដើម ឬក៏អាចជួយឲ្យបាននូវភាពជាទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មជាដើម ឬភាពដ៏ធំលើសពីនោះទៅទៀតក៏សឹងបានដែរ ។

៣)– ឥច្ឆា នរំ បរិកស្សតិ សេចក្តីប្រាថ្នារមែងកើតកន្ត្រាក់នរជនយកទៅ, បានជាអង្គព្រះអនាវរណញ្ញាណទ្រង់ត្រាស់សំដែងថាដូច្នេះ ពីព្រោះពាក្យថា ឥច្ឆា មួយម៉ាត់នេះ ជាឈ្មោះរបស់ឧបក្កិលេសមួយ ដែលតែងដើរតាមផ្ទន្ទាយាយីពួកសត្វលោក ឬតែងតាមធ្វើឲ្យសត្វវិលវល់នៅក្នុងវាលវដ្តសំសារមិនឲ្យស្វែងរកផ្លូវត្រូវគឺអដ្ឋង្គិកមគ្គទាំង ៨ ដែលជាផ្លូវដ៏ត្រង់ សម្រាប់ពពួកសត្វធ្វើការសញ្ចរណ៍ទៅកាន់អមតមហាបុរី , ទុកជាអ្នកណាក៏ដោយ លើកលែងតែព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងអរិយសាវកជាដើមចេញ ក្រៅអំពីនេះ គង់តែគេចមិនផុតពីកណ្តាប់ដៃឥច្ឆានេះដែរ,

មជ្ឈមណ្ឌលឯកសារកម្ពុជា
បណ្ណាល័យ
លេខកូដ : ..........

សេចក្តីនេះសមដូចពុទ្ធភាសិត ដែលព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ទុកក្នុង គម្ពីរធម្មបទដ្ឋកថា ខុទ្ទកនិកាយ ត្រង់ធម្មដ្ឋវគ្គ ថា:

ន មុណ្ឌកេន សមណោ អព្វតោ អលិកំ ភណំ
ឥច្ឆាលោភសមាបន្នោ សមណោ កឹ ភវិស្សតិ

ប្រែថា: បុគ្គលមិនមែនជាសមណៈ ដោយគ្រាន់មានក្បាលត្រងោល ប៉ុណ្ណោះទេ, បុគ្គលដែលមិនមានវត្តប្រតិបត្តិល្អ និយាយតែពាក្យឡេះ ឡោះ សម្បូណ៌ទៅដោយឥច្ឆានិងលោភៈ នឹងទៅជាសមណៈដូចម្តេចកើត ។

៤– ឥច្ឆា លោកស្មិំ ទុជ្ជហា សេចក្តីប្រាថ្នាកម្របុគ្គលលះបង់បានក្នុងលោក ហេតុអ្វីបានជាព្រះបរមគ្រូ ទ្រង់ត្រាស់សំដែងថាដូច្នេះ បានជាព្រះអង្គត្រាស់ថាដូច្នេះ ព្រោះសេចក្តីប្រាថ្នានេះ តែងជិតជាប់មាំក្នុងសន្តាន សត្វទាំងឡាយមិនហ៊ាននឹងបោះបង់ចោលបានឡើយ ដោយហេតុសេចក្តីប្រាថ្នានេះព្រះពុទ្ធជាម្ចាស់ត្រាស់ថា ប្រសិនបើជាមានរូបរាងមិនអាចនឹងយកទៅទុកដាក់ក្នុងទីណាឲ្យអស់ឡើយ ចក្កវាឡទូលាយធំល្វឹងល្វើយដល់ម្លឹង ក៏គង់នៅតែចង្អៀត មិនអាចនឹងដាក់សេចក្តីប្រាថ្នារបស់សត្វលោកឲ្យអស់ដែរ ព្រះពុទ្ធជាម្ចាស់របស់យើង ដែលទ្រង់កសាងសន្សំអប់រំបំពេញបារមី អស់រយៈកាលចំនួន ៤ អសង្ខេយ្យនិងមួយ

សែនកប្ប ឥតគិតគូរត្រង់ការនឿយព្រួយលំបាកសោះ ព្រោះតែប្រាថ្នាចង់គេចរួចអំពីតណ្ហានេះ ហើយនឹងចប់នូវសត្វឯកក៏ព្រោះខ្វានប៉ុណ្ណោះ ។

៥– ឥច្ឆា ពទ្ធា បជា សត្តា បាសេន សកុណី យថា

សត្វមានកិលេសក្រាស់ រមែងជាប់នៅក្នុងសេចក្តីប្រាថ្នា ដូចជាបក្សីជាប់អន្ទាក់, បានជាព្រះអង្គទ្រង់ដោះស្រាយបញ្ហានេះថាដូច្នេះ ព្រោះសត្វដែលកើតមកក្នុងលោកសន្និវាសនេះ មិនថាជាតិណា សាសន៍ណា ត្រកូលណា គោត្រណាឡើយ អ្នកណាក៏ដោយ ដែលតែបានកើតក្នុងលោកសន្និវាសនេះ បើកើតក្នុងលោកនេះហើយ សុទ្ធតែចូលក្នុងអន្ទាក់របស់តណ្ហាទាំងអស់ដូចជាសត្វសកុណជាតិដែលជាប់លប់របស់ព្រានសត្វស្លាប, តែជាប់ហើយមិនងាយនឹងរើរួចទេ, អ្នកដែលមិនជាប់សំណាញ់អន្ទាក់នេះបានតែព្រះធម្មរាជ ព្រះបច្ចេកពុទ្ធនិងអរិយសាវកជាដើមនោះរៀបរយ, សេចក្តីប្រាថ្នានេះ តែគ្រប់សង្កត់ទៅលើអ្នកណាមួយ ហើយមិនឱ្យអ្នកនោះរើខ្លួនរួចទេ តែងធ្វើអ្នកនោះឱ្យលំបាកកោកកើតវេទនាហិនហោចខ្ទាចខ្ទីរកពេលទំនេរគ្មាន សេចក្តីនេះ សមដូចជាពុទ្ធភាសិតមួយទៀត ក្នុងគម្ពីរទសកនិបាត ចតុក្កជាតកបាឋ:

ឥច្ឆាហតស្ស បោសស្ស ចក្កំ ភមតិ មត្ថកេ ចក្រតែងវិលលើក្បាលនៃសត្វ ដែលត្រូវសេចក្តីប្រាថ្នាគ្របសង្កត់ ។

សេចក្ដីដែលអធិប្បាយស្រង់ស្រាយបកពីខាងលើនេះមានប៉ុន្មាន ប្រជុំចុះក្នុងធម៌តែ ៣ មាត់ប៉ុណ្ណោះគឺ សទ្ធា ១, សីល ១, បញ្ញា ១, ។

# អធិប្បាយអំពីសទ្ធា

ធម៌ទី ១

ពាក្យថា សទ្ធានេះជាសោភណចេតសិក ប្រព្រឹត្តទៅក្នុងពួកសោភណចិត្ត ជាធម្មជាតិ ជឿចំពោះរបស់ដែលគួរជឿ មានជឿកម្មនិងផលរបស់កម្មជាអាទិ៍, បើនិងពោលដោយប្រភេទ, សទ្ធាមាន ២ យ៉ាងក៏មាន ៣ យ៉ាងក៏មាន, ៤ យ៉ាងក៏មាន ។

## សទ្ធា ២ យ៉ាងគឺ

១– លោកិយសទ្ធា ធម្មជាតិជឿកម្មនិងផលរបស់កម្មជាដើម តែនៅកម្រើកដោយលោកធម៌ ៨ យ៉ាងគឺ: មានលាភ, ឥតលាភ: មានយស ឥតយស, មានកេរ្តិ៍ឈ្មោះ, ឥតកេរ្តិ៍ឈ្មោះ, សុខនិងទុក្ខ, កាលបើមានលាភ, យស, កេរ្តិ៍ឈ្មោះ និងមានសេចក្ដីសុខ សេចក្ដីចំរើនកើតឡើងហើយ ក៏តែងសោយសោមនស្សវេទនា បើប្រសិនណាឥតលាភ, ឥតយស, ឥតកេរ្តិ៍ឈ្មោះនិងបានទុក្ខលំបាកវិញ ក៏ប្រែទៅជាសោយទោមនស្សវេទនានេះហៅថា ចលសទ្ធា ដែលជាសទ្ធានៅកម្រើកញាប់ញ័រ បានដល់សទ្ធារបស់បុគ្គលជាបុថុជ្ជន ។

២–លោកុត្តរសទ្ធា ធម្មជាតិជឿកម្មនិងផលរបស់កម្ម មិនកម្រើកដោយលោកធម៌ទាំង ៨ ប្រការទុកជាមានលោកធម៌ណាមួយ ចូលមកប៉ះពាល់ក៏ដោយគង់តែមិនសោយសោមនស្ស ទោមនស្សឡើយ ត្រង់ហ្នឹងឯង ហៅថា អចលសទ្ធា បានដល់សទ្ធារបស់ព្រះអរិយបុគ្គល ។

## សទ្ធា ៣ យ៉ាងគឺ

១–បសាទសទ្ធា ធម្មជាតិជឿច្បាស់លាស់អាចឲ្យមានសេចក្តីជ្រះថ្លា មិនកករល្អក់ដោយលោភ(១) និងមច្ឆរិយ(២) ។

២– ឱកប្បនសទ្ធា ជំនឿដែលតាំងនៅមាំក្នុងវត្ថុដែលគួរជឿ ។

៣– អចលសទ្ធា ជំនឿមិនរំកើបញាប់ញ័រ ។

## សទ្ធា ៤ យ៉ាងគឺ:

១ – កម្មសទ្ធា ធម្មជាតិជឿកម្ម គឺជឿថាអំពើអាក្រក់, ល្អ, បាប, បុណ្យ, គុណ, ទោសមានពិតប្រាកដ ១ ។

---

១– លោភមាន ២ យ៉ាងគឺ:សមលោភ ១ វិសមលោភ ១

២– មច្ឆរិយ ៥ យ៉ាងគឺ: អាវាស ១, កុល ១, លាភ ១, វណ្ណ ១, ធម្ម ១ ។

២– វិបាកញ្ញាណ ធម្មជាតិដឹងផលរបស់កម្ម គឺដឹងផលដែល
កើតអំពីកម្មនោះៗ ថាកម្មសឲ្យផលស, កម្មខ្មៅឲ្យផលខ្មៅ, កម្មសខ្លះខ្មៅ-
ខ្លះ ឲ្យផលសខ្លះខ្មៅខ្លះ, កម្មមិនសមិនខ្មៅ ឲ្យផលមិនសមិនខ្មៅ ១ ។

៣– កម្មស្សកតាញ្ញាណ ធម្មជាតិដឹងថាសត្វមានកម្មជារបស់
ខ្លួន មានកម្មជាកេរ្តិ៍មត៌ក មានកម្មជាកំណើត មានកម្មជាផៅពង្ស មាន
កម្មជាគ្រឿងនឹកឃើញ បើសត្វធ្វើកម្មឯណា ជាកុសលក្តី ជាអកុសលក្តី
នឹងត្រូវទទួលមត៌ក គឺផលនៃកម្មនោះៗ ១ ។

តថាគតពោធិញ្ញាណ ធម្មជាតិដឹងកិរិយាត្រាស់ដឹងរបស់ព្រះ
តថាគតគឺដឹងថាព្រះដ៏មានភាគអង្គនោះ ព្រះអង្គទ្រង់ព្រះនាមថា អរហំ
ថា សម្មាសម្ពុទ្ធោ ជាដើមពិតប្រាកដ ព្រមទាំងដឹងធម៌ជាគ្រឿងត្រាស់ដឹងនៃ
ព្រះតថាគតថាបណ្តាធម៌ទាំង ៣៧ ប្រការគឺ សតិប្បដ្ឋាន ៤, សម្មប្បធាន ៤,
ឥទ្ធិបាទ ៤, ឥន្ទ្រិយ ៥, ពល ៥, ពោជ្ឈង្គ ៧, និងមគ្គប្រកបដោយអង្គ ៨,
ទាំងអស់នេះជាធម៌ប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណ ១ ។

សួរថា សត្វមានអ្វីជារស?

ឆ្លើយថា សត្វមានចិត្តស្អាតបរិសុទ្ធមិនបាន
ករដោយកិលេស គឺលោភៈ ទោសៈ មោហៈ ជារស ។

សួរថា សទ្ធា មានអ្វីជាប្រធាន?

ឆ្លើយថា សទ្ធា មានរតនៈទាំង៣ជាប្រធាន ។

សួរថា សទ្ធាមានអ្វីជាកេរ្តិ៍?

ឆ្លើយថា សទ្ធាមានកម្មនិងផលនៃកម្មជាកេរ្តិ៍ ។

សួរថា សទ្ធា មានអង្គប៉ុន្មាន? គឺអ្វីខ្លះ?

ឆ្លើយថា សទ្ធាមានអង្គ ៤ គឺ:

១– សប្បុរិសូបសំសេវ សេពគប់តែនឹងសប្បុរស

២– ធម្មស្សវនំ ស្តាប់ធម៌របស់អ្នកសប្បុរស

៣– យោនិសោមនសិការ យកធម៌មកធ្វើទុកក្នុងចិត្ត ដោយឧបាយនៃប្រាជ្ញា ។

៤– ធម្មានុធម្មប្បដិបត្តិ ប្រតិបត្តិនូវធម៌តាមសមគួរដល់ធម៌

សួរថា សទ្ធា មានលក្ខណៈប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

ឆ្លើយថា សទ្ធា មានលក្ខណៈ ៤ យ៉ាងគឺ

១– សទ្ទហនលក្ខណាសទ្ធា សទ្ធាមានការជឿជាលក្ខណៈ ។

២– បសាទលក្ខណាសទ្ធា សទ្ធាមានសេចក្តីជ្រះថ្លាជាលក្ខណៈ ។

៣– បក្ខន្ទលក្ខណាសទ្ធា សទ្ធាមានកិរិយាលឿនទៅជាលក្ខណៈ ។

## ៤– ឱកប្បនលក្ខណាសទ្ធា សទ្ធាមានកិរិយាតាំងនៅ

ក្នុងវត្ថុដែលគួរជឿជាលក្ខណៈ ។

សទ្ធានេះព្រះអរហំសម្ពុទ្ធជាមកុដនៃត្រកូល ត្រាស់ហៅថាជាមេគាថបណ្ដុះបណ្ដាល សហជាតធម៌ឯទៀត ៗ ដែលជាកុសលឲ្យកើតឡើងជាមួយនឹងខ្លួន គឺថាអាចនឹងទទួលភារកិច្ចជាអ្នកកើបទាញដឹកនាំចិត្តនរជនឲ្យព្យាយាមបំពេញកុសលធម៌ត្រាតែសម្រេចតាមសមគួរ ដល់សេចក្ដីប្រាថ្នា ដូចជានឹមដែលអាចទទួលបន្ទុកភារៈនៃយានទាំងមូល ហើយនាំទៅបានដូរបោះដែរ ។ មិនត្រឹមតែប៉ុណ្ណោះទេ, សទ្ធានេះមានមហិទ្ធានុភាពប្រព្រឹត្តទៅដោយន័យផ្សេង ៗ គឺចាត់ជាធំជាងសហជាតធម៌ទាំងពួងហៅថាសទ្ធិន្ទ្រិយក៏មាន,. ចាត់ជាពូជនៃកុសលធម៌ ហៅថាសទ្ធាពីជក៏មាន, ចាត់ជាទ្រព្យដ៏ប្រសើរសម្រាប់ប្រើប្រាស់របស់បុរសស្ត្រីក្នុងបរលោក ហៅថាសទ្ធាធនក៏មាន, ចាត់ជាកម្លាំងសម្រាប់ប្រឆាំងនឹងសឹកសង្គ្រាមគឺពាក្កិលេសឲ្យចាលចាញ់ហៅថាសទ្ធាពលក៏មាន, ចាត់ជាក្បូនឬទូកសម្រាប់ឆ្លងនូវអន្លង់ទាំង ៤ ហៅថាសទ្ធានាវាក៏មាន, ចាត់ជាប្រេងឬជ័រសម្រាប់លាបលនចិត្តដែលរបើងរើរូស ឲ្យជាចិត្តទន់ងាយពត់ដម្រង់ឲ្យត្រង់ទៅរកមគ្គផលនិព្វាន ហៅថាសទ្ធាសិនេហាក៏មាន ។

សទ្ធាដែលសំដែងមកទាំងអស់នេះ សុទ្ធតែសម្បយុត្តដោយបញ្ញា; បុគ្គលអ្នកមានសទ្ធា ដូចបានអធិប្បាយមកខាងលើនេះ ទោះបីគាត់ទៅកន្លែងណាគង់មានគេបូជាកន្លែងនោះមិនខានឡើយ ។ គួរយ៉ាងដូចជាចិត្តគហបតីដែលទេវតានិងមនុស្សទាំងឡាយតែងបូជា,

មានសេចក្តីដំណាលថា គ្រាមួយនោះ, ព្រះអានន្ទត្ថេរក្រាបបង្គំទូលសួរព្រះអរហំសម្មាសម្ពុទ្ធថា បពិត្រព្រះអង្គដ៏ចំរើន ចិត្តគហបតីនេះមកកាន់សំណាក់ព្រះអង្គអស់មួយថ្ងៃ ហើយនៅកន្លែងនេះអស់មួយថ្ងៃទៀត ទេវតានិងមនុស្សទាំងឡាយតែងតែបូជាគ្រឿងសក្ការៈដល់គាត់រាល់ ៗ ថ្ងៃ គាត់ឲ្យបានតែគ្រឿងសក្ការៈដែលទេវតានិងមនុស្សទាំងឡាយនាំមកបូជានោះ ឥឡូវនេះគាត់យករទេះទាំង ៥០០ ត្រឡប់មកវិញ ពួកទេវតានិងមនុស្សក៏នាំគ្នាឈូងរយករតនៈ ៧ ប្រការ មកដាក់បំពេញរទេះគ្រប់ ៗ ទាំងអស់; ឮល្បីថាគាត់ទុកបំរើមហាជន . ដោយគ្រឿងសក្ការៈដែលគាត់នាំមកប៉ុណ្ណោះបពិត្រព្រះអង្គដ៏ចំរើន គ្រឿងសក្ការៈកើតឡើងដល់ចិត្តគហបតីនេះតែកន្លែងពេលដែលមកកាន់សំណាក់ព្រះអង្គនេះឬ? ឬថាកើតឡើងដល់គាត់ដែលទៅកន្លែងដទៃដែរ? ។ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលអានន្ទ ចិត្តគហបតីនេះ ទោះបីមកកាន់សំណាក់តថាគតក៏

ដោយ ទោះទៅក្នុងទីដទៃទៀតក៏ដោយ គ្រឿងសក្ការៈ តែងតែកើតឡើង ដល់គាត់ជានិច្ច ព្រោះឧបាសកនេះជាអ្នកមានសទ្ធាជ្រះថ្លា, បរិបូណ៌ដោយ សីលបើទុកជាគប់រកទៅប្រទេសណា ៗ លាភសក្ការៈតែងកើតឡើងដល់ គាត់ក្នុងប្រទេសនោះៗ ហើយទ្រង់សំដែងគាថានេះ ក្នុងបកិណ្ណកវគ្គ ថា:

សទ្ធោ សីលេន សម្បន្នោ យសោ ភោគសមប្បិតោ
យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

ប្រែថា បុគ្គលដែលជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល ជាអ្នក ឆ្អែតស្កប់ស្កល់ដោយយសនិងភោគៈ បើគប់រកទៅប្រទេសណា ៗ, ក្នុង ប្រទេសនោះ ៗ ឯង គេតែងតែបូជាមិនខាន ។

កាលបើព្រះភគវន្តមុនីសម្ពុទ្ធជាម្ចាស់ ទ្រង់សំដែងយ៉ាងនេះហើយ ព្រះអានន្ទត្ថេរ ក៏ក្រាបបង្គំទូលសួរបុព្វកម្មរបស់ចិត្តគហបតីនោះ ។

គ្រានោះព្រះដ៏មានបុណ្យទ្រង់សំដែងថា ម្នាលអានន្ទ ចិត្តគហបតីនេះ បានការកសាងធ្វើទុកហើយ ទៀបបាទមូលនៃព្រះពុទ្ធទ្រង់ព្រះនាម បទុមុត្តរ, បានអន្ទោលទៅមកក្នុងទេវតានិងមនុស្សទាំងឡាយអស់មួយ សែនកប្ប. លុះដល់សាសនាព្រះពុទ្ធព្រះនាមកស្សប បានច្យុតចាក ទេវលោកមកកើតក្នុងត្រកូលព្រានម្រឹគ ។ ថ្ងៃមួយជួនជាពេលមានភ្លៀង

ផ្កាក់ដោតជាំ គាត់ក៏កាន់លំពែងដើរចូលទៅក្នុងព្រៃរកបាញ់ម្រឹគ ស្រាប់
តែឃើញភិក្ខុ ១ រូបទទួលចីពរឈរនៅក្បែរញកភ្នំ គាត់គិតថាលោកម្ចាស់
នេះប្រហែលជាធ្វើសមណធម៌ អញនឹងប្រគេនចង្ហាន់លោកបានម្ដងរេះ
ទើបគាត់យាំងប្រញាប់ប្រញាល់ប្រាប់ភរិយាឲ្យចំអិនសាច់ ដែលខ្លួនរកបាន
ពីថ្ងៃម្សិល ពេលនោះមានភិក្ខុ ១ រូបទៀតកំពុងដើរបិណ្ឌបាត ក៏និមន្តលោក
ឲ្យគង់លើអាសនៈដ៏សមគួរ, ប្រគេនចង្ហាន់ដល់បិណ្ឌបាតិកភិក្ខុនោះស្រួល
បួលហើយក៏យកចង្ហាន់ប្រគេនលោកដែលនៅក្បែរញកភ្នំ លុះដើរទៅ
ដល់កណ្ដាលផ្លូវក៏បេះផ្កាយកទៅផង កាលបើដើរទៅដល់ជួបនឹងលោក
ហើយគាត់ទូលលោកថា សូមលោកម្ចាស់ធ្វើសេចក្ដីសង្គ្រោះដល់ខ្ញុំព្រះ
ករុណាផង រួចយកចង្ហាន់ដាក់បាត្រលោកពេញ ហើយបូជាផ្កានោះទៀត
ទើបធ្វើសេចក្ដីប្រាថ្នាថា៖ ចង្ហាន់បិណ្ឌបាតនឹងការបូជាផ្ការបស់ខ្ញុំព្រះករុណា
នេះ ដែលញុំាងចិត្តខ្ញុំព្រះករុណាឲ្យត្រេកអរយ៉ាងណា គ្រឿងបណ្ណាការ
ទាំងពាន់ៗ ចូរកើតដល់ខ្ញុំព្រះករុណារាល់ៗជាតិ ព្រមទាំងផ្កាដែលបាន
ពណ៌ ៥ ក៏សូមបង្អុរចុះមករាល់ៗជាតិ ត្រង់កន្លែងដែលខ្ញុំកើតកុំបីឃ្លៀង
ឃ្លាតឡើយៗ ព្រាននេះធ្វើកុសលដរាបដល់អស់ជីវិត ក៏បានទៅកើតក្នុង
ទេវលោក ឯគ្រឿងផ្កាទិព្វក៏បង្អុរជាផ្កាៗ ត្រឹមៗ ជង្គង់ក្នុងទីដែលគាត់
កើតនោះឯងៗ ឥឡូវនេះគ្រឿងផ្កាម្ទេះនឹងគ្រឿងបណ្ណាការ នឹងកែវ

៧ ប្រការកើតដល់គាត់ជានិច្ចកាលនេះឯងជាអានិសង្សនៃកម្មដែលហូរជូន
មកមិនដាច់ដល់គាត់ដូចបានថ្លែងមកនេះ ។

សទ្ធារបស់ព្រាន ដែលជឿជាក់ចំពោះព្រះថេរៈមិនទាន់ជាស៊ប់សួនប៉ុន្មានទេ; បើឲ្យផលដល់ម្លឹងទៅហើយ ចុះទំរាំបើជឿជាក់ស៊ប់សួនទៅទៀតនឹងឲ្យផលបែបណាទៅវិញ[1] ដូចយ៉ាងនាងធនញ្ជានីព្រាហ្មណីជាប្រពន្ធ បិណ្ណាលការទ្វាជព្រាហ្មណ៍ នាងនេះជាស្ត្រីបានលុះដល់ថ្នាក់សោតាបត្តិផល មានសទ្ធាជ្រះថ្លាចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ, ឯព្រាហ្មណ៍ឈ្មោះបិណ្ណាលការទ្វាជៈ ជាមនុស្សមិច្ឆាទិដ្ឋិ គ្រាន់តែឮពាក្យថា ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃដូច្នេះ គាត់ខ្ទប់ត្រចៀកមិនឲ្យឮទេ[1] ជាមនុស្សរឹងរឹងរូសដូចជាដង្គត់ឈើគគី ។ ឯនាងធនញ្ជានីឈរក្តីអង្គុយក្តី ដើរក្តី ក្អកក្តី កណ្តាសក្តី តែងស្ញើនមស្ការថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ដូច្នេះ ។ គាប់ជួនជាថ្ងៃមួយ ព្រាហ្មណ៍ប្តី ចង់ប្រគេនអម្បៀងកមធុបាយាសដល់ពួកព្រាហ្មណ៍ក៏និមន្តព្រាហ្មណ៍ឲ្យទានក្នុងវេលាព្រឹក ទើបគាត់និយាយនឹងព្រាហ្មណីថា «ក្នុងថ្ងៃស្អែកនេះ យើងនិមន្តព្រាហ្មណ៍ ៥០០ មកឆាន់ក្នុងផ្ទះយើង នាងឯងធ្លាប់ស្ញើនមស្ការចំពោះសមណៈត្រងោលយូរហើយ តែក្នុងថ្ងៃស្អែកនេះ នាងឯងកុំស្ញើនមស្ការចំពោះសមណៈត្រងោលនោះ

ឲ្យសោះ ព្រោះបើព្រាហ្មណ៍ទាំងឡាយនេះឮនូវពាក្យនោះកាលណាហើយ លោកមិនសព្វព្រះទ័យទេ ហេតុនេះនាងឯងកុំធ្វើឲ្យអញវិនាសឡើយ ។ នាងព្រាហ្មណីនិយាយថា អ្នកបែកអំពីព្រាហ្មណ៍ក៏ដោយ អំពីទេវតាក៏ដោយ ត្រង់ឲ្យខ្ញុំខានវត្តការនមស្ការ ចំពោះព្រះសាស្តាមិនបានទេ ព្រាហ្មណ៍ឮដូច្នោះក៏កាន់នូវដាវ ហើយនិយាយថា ម្នាលនាងព្រាហ្មណី ប្រសិនបើព្រាហ្មណ៍ទាំងឡាយមកកន្លែងស្រុកហើយក៏ពុំអង្គុយ នាងឯងកុំនមស្ការស្រមណ៍គោតមឲ្យសោះ បើនាងឯងនៅតែធ្វើវិញ អញនឹងកាត់ក្បាលនាងឯងដោយដាវនេះមិនខាន ។

ធម្មតាអរិយសាវកទាំងឡាយ មានហឫទ័យដូចជាផែនដីដែលបុគ្គលមិនអាចឲ្យរលកម្រើកបានផង ដូចជាភ្នំសិនេរុដែលបុគ្គលមិនអាចត្រឡប់បានផងព្រោះហេតុនោះ បានជានាងព្រាហ្មណីនិយាយយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បើប្រសិនជាអ្នកកាត់អវយវៈតូចធំរបស់ខ្ញុំបានដោយពិត ត្រង់ដែលឲ្យខ្ញុំវៀរចាកសាសនារបស់ព្រះពុទ្ធៈប្រសើរមិនបានទេ ព្រាហ្មណ៍ក៏មិនអាចធ្វើទុក្ខបុកម្នេញដល់នាងបានដែរ ហើយនិយាយថានាងឯងគាប់ចិត្តធ្វើបែបណា ក៏ធ្វើតាមគាប់ចិត្តបែបនោះចុះ ហើយក្រវែងដាវចោលលើទីដីណោក, លុះព្រឹកឡើងព្រាហ្មណ៍ ចាត់ចែងបាយបាយាសដល់

ព្រាហ្មណ៍ទាំងឡាយ ហើយប្រើមនុស្សឲ្យទៅអញ្ជើញពួកព្រាហ្មណ៍តាម
កាលកំណត់, ព្រាហ្មណ៍ទាំងឡាយនោះមកអង្គុយត្រៀបត្រាលើអាសនៈ
ដ៏សមគួរ ៗ ឯព្រាហ្មណ៍កំពុងតែអង្គុយលើអាសនៈជាមួយនឹងព្រាហ្មណ៍
ទាំងឡាយនោះ គ្រានោះនាងព្រាហ្មណីកាន់នូវវែកមាសមកអង្គាសពួក
ព្រាហ្មណ៍គង់រង់ភត្ត កំពុងតែរៀបចំនូវភត្ត ក៏ភ្លាត់ជើងដួលទៅលើជ្រញ់
ឈើដែលគេដាក់មិនស្រួល សេចក្តីទុក្ខវេទនា ក៏កើតឡើងដល់នាង ខណៈ
នោះនាងនឹករឭកដល់ព្រះសាស្តា ក៏ផ្គងអញ្ជលីដាក់លើសិរសា វត្តវេឡុវ័ន-
នៅទីណា ក៏ផ្គងអញ្ជលី ដម្រង់ទៅទីនោះ ហើយបន្លឺឧទានវាចាអស់
វារៈបីដងថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស
ដូច្នេះខណៈនោះព្រាហ្មណ៍ទាំងឡាយ ខ្លះបរិភោគហើយ ខ្លះកំពុងបរិភោគ
ខ្លះកំពុងពម ខ្លះទើបនឹងរៀបបរិភោគ ខ្លះកំពុងត្រលប់ដៃ គ្រាន់តែឮសំ
ឡេងនោះភ្លាម ដូចជាគេយកអង្រែបុកស៊ុនមកសំពង់បំអំបែងក្បាល,
ហើយទឹងនឹងព្រាហ្មណ៍ក៏ពោលថា យើងត្រូវព្រាហ្មណ៍មានលទ្ធិដទៃឲ្យ
ចូលមកកាន់ផ្ទះ ព្រាហ្មណ៍ណាដែលកំពុងកាន់បាយ ក៏បោះចោលទៅ
ព្រាហ្មណ៍ណាដែលកំពុងបរិភោគក៏ព្រួស-ចេញមកវិញ ហើយដេរ
ព្រាហ្មណ៍ជាអនេកប្រការ រួចចៀសចេញទៅ ៗ នៅមាននិទានពិស្តារ
តទៅទៀត តែផ្ទៀតផ្ទាត់មកថ្លែងទុកដោយសង្ខេបប៉ុណ្ណេះក្នុងទីនេះ ជា

គ្រឿងប្រដាប់ដល់បញ្ញាពិចារណា ក៏សូមបញ្ចប់ធម្មកថាត្រឹមបទថា សន្តាពន្ធុំ បារថយ្យំ ដោយសង្ខិតកថា ។

---

## អធិប្បាយអំពីសិរី

### ធម៌ទី ២

ពាក្យថាសិរី មានន័យច្រើនបែបណាស់ "សិរី" ប្រែថា ស្រី, ល្អ, សម្បត្តិ, ទេវតា, សេចក្ដីចំរើន, សុខ, សួស្ដី; មង្គល មួយទៀតមានបទវិគ្គហ ក្នុងអភិធានប្បទីបិកាសូចិថា: កតបុញ្ញេ ហិ; សេវតីតិ " សិរី ធម្មជាតិ តែងសេពគឺអាស្រ័យនៅជាមួយនឹងអ្នកដែល បានធ្វើបុណ្យកុសល ។

ឯពាក្យថា « សិរី » បើប្រែថា « បុណ្យ ឬផលបុណ្យក៏បានព្រោះ មានបទមួយក្នុងគម្ពីរមង្គលត្ថទីបនីថា:អបិច យស្មា អកតបុញ្ញោ អានុភាវសម្បន្នំ វត្ថុំ លភិត្វាបិ ទុក្ខំ បាបុណាតិ កតបុញ្ញោ សុខំ យស្មា ច អកតបុញ្ញោ បរេហិ ទិន្នំបិ សិរី គហេតុំ ន សក្កោតិ សា សិរី. បុញ្ញវន្តមេវុបគតា តស្មាបិ បុញ្ញំ កតបុញ្ញតា មង្គលន្តិ វុច្ចតិ ។

ប្រែ: ន័យមួយទៀតថា មនុស្សជាអកតបុញ្ញបុគ្គល សូម្បីបាន វត្ថុដែលបរិបូណ៌ដោយអានុភាពយ៉ាងណាក៏ដោយ ក៏ដល់នូវសេចក្ដីទុក្ខ

វិញមិនខាន ឯមនុស្សជាកតញ្ញូបុគ្គល បើបានវត្តបែបនោះ ក៏គង់បានសេចក្ដីសុខជាប្រាកដ រីឯអកតញ្ញូបុគ្គលមិនអាចទទួលយកនូវសិរីដែលអ្នកដទៃឲ្យឡើយ សិរីនោះឯងតែងចូលទៅរកបុគ្គលអ្នកមានបុណ្យជាប្រាកដ ព្រោះហេតុឯណា ព្រោះហេតុនោះឯង ភាពនៃបុគ្គលអ្នកមានបុណ្យធ្វើហើយបុណ្ឌិតគប្បីយល់ថាជាមង្គលដ៏ប្រសើរ ។

ឯសិរី បើនរណាគ្មានហើយ ទឹងកាន់យកដោយការលួចប្លន់ក្ដី ឆក់ដណ្ដើមក្ដី ឬមួយសុំអំពីបុគ្គលដទៃដែលគេមានយកមកដើម្បីខ្លួនក្ដី ទុកជាម្ចាស់សិរីឲ្យហើយ ក៏យកជាទ្រព្យរបស់ខ្លួនមិនបានឡើយ ដូចជា សិរីលក្ខណព្រាហ្មណ៍ដែលគាត់សុំសិរីអំពីអនាថបិណ្ឌិកសេដ្ឋី ។ ឲ្យហើយតែសិរីមិនអាចទៅអាស្រ័យនៅនឹងព្រាហ្មណ៍សុំទេ មានសេចក្ដីដំណាលថា មានព្រាហ្មណ៍ម្នាក់ឈ្មោះសិរីលក្ខណៈ ជាអ្នកចេះមើលសិរី នៅក្នុងក្រុងសាវត្ថី ។ សម័យថ្ងៃមួយ ព្រាហ្មណ៍នោះគិតថា សេដ្ឋីនេះកាលពីដើម ជាអ្នកក្រីក្រលំបាកពេកណាស់ ឥឡូវនេះបានឡើងឋានៈ ជាអ្នកមានស្ដុកស្ដម្ភព្រោះគាត់មានសិរី បើដូច្នោះមានតែអញទៅលួចយកសិរី ហើយសឹមត្រឡប់មកវិញ លុះគិតដូច្នោះហើយ ក៏ដើរទៅកាន់ផ្ទះអនាថបិណ្ឌិកសេដ្ឋីនោះមួយរំពេច ។ លុះព្រាហ្មណ៍ដើរទៅដល់ផ្ទះនោះ សេដ្ឋីក៏ទទួលដោយសេចក្ដីរាក់ទាក់ ហើយសួរថា

អ្នកមកមានការអ្វី? ព្រាហ្មណ៍ក៏រវៃរំពឹងដញ្ញឹង រកមើលថាសិរីបិតនៅក្នុងទីណា ។ លុះដឹងថានៅលើសិរីមាន់ក៏និយាយថា បពិត្រមហាសេដ្ឋី ខ្ញុំជាអ្នកបង្រៀនមន្តដល់មាណពទាំង ៥០០ នាក់ យើងលំបាកណាស់ មានមាន់មួយរងាវខុសកាល ព្រោះថាមាន់របស់លោកចេះរងាវត្រូវកាលវេលា បានជាខ្ញុំមកព្រោះតែមាន់ហ្នឹង ហេតុនេះសូមលោកឲ្យមាន់នេះដល់ខ្ញុំ ។ សេដ្ឋីនិយាយថា ម្នាលព្រាហ្មណ៍ អ្នកឯងចូរយកចុះ, គួរអស្ចារ្យណាស់ ក្នុងពេលដែលសេដ្ឋីគ្រាន់តែហាមាត់ថាឲ្យប៉ុណ្ណោះ សិរីក៏ប្រាសចេញអំពីសិរីមាន់ទៅស្ថិតនៅលើកែវមណីដែលគាត់ដាក់លើក្បាលដំណេក, ព្រាហ្មណ៍ដឹងហេតុនោះភ្លាមក៏សុំកែវមណីទៀត ក្នុងខណៈដែលសេដ្ឋីនិយាយថាខ្ញុំឲ្យសិរីក៏ប្រាសចេញអំពីកែវមណីនោះទៅនៅលើឈើច្រត់ដែលគាត់ដាក់លើក្បាលដំណេក, ព្រាហ្មណ៍ដឹងហេតុនោះភ្លាមក៏សុំឈើច្រត់ទៀត សេដ្ឋីក៏ឲ្យទៀតសិរីក៏ប្រាសចេញពីនោះ . ទៅនៅលើក្បាលនៃអគ្គមហេសីរបស់សេដ្ឋីឈ្មោះបុញ្ញលក្ខណទេវី ។ លុះព្រាហ្មណ៍ដឹងដូច្នោះហើយ ក៏គិតថា របស់នេះគេមិនគប្បីលះបង់បាន អញមិនអាចនឹងសុំទេ ទើបនិយាយប្រាប់សេដ្ឋីតាមត្រង់ថា ខ្ញុំមិនអាចនឹងលួចសិរីរបស់លោកបានទេ វត្ថុជារបស់លោកចូរនៅជារបស់លោកដដែលចុះ ហើយលាសេដ្ឋីទៅផ្ទះវិញ ។

ព្រោះហេតុនោះ សិរីរមែងសម្រេចដោយអានុភាពនៃបុណ្យ សិរីនោះបើតាមសេចក្ដីពិត គឺបានដល់សម្បត្តិរបស់បុណ្យ និងកំលាំងរបស់បុណ្យតែម្យ៉ាង ព្រោះហេតុ បុគ្គលដែលមិនមានបុណ្យ មិនអាចនឹងទទួលយកសិរី ដែលបុគ្គលដទៃឲ្យហើយបានទេ ។

ព្រោះហេតុដូច្នោះ បានជាព្រះលោកុត្តមាចារ្យទ្រង់ត្រាស់ព្រះគាថា ក្នុងសិរីខោរជាតក តិកនិបាតថា៖

យំ ឧស្សុក្កា សង្ឃរន្តិ ពហុំ ធនំ
សិប្បវន្តោ អសិប្បាវា លក្ខិ តានិ ភុញ្ជតិ
សព្វត្ថ កតបុញ្ញស្ស អតិច្ចញ្ញេវ បាណិនោ
ឧប្បជ្ជន្តិ ពហូ ភោគា អបនាយតនេសុបិ ។

ប្រែថា ពួកអ្នកឥតបុណ្យ ទោះមានសិប្បៈក្ដី ឥតសិប្បៈក្ដី ខ្វល់ខ្វាយប្រមូលនូវទ្រព្យច្រើនឯណា អ្នកមានបុណ្យហ្នឹងឯងតែងបរិភោគប្រើប្រាស់ នូវទ្រព្យច្រើនទាំងនោះ ភោគៈទាំងឡាយច្រើន រមែងកន្លងនូវពួកសត្វដទៃ កើតឡើងដល់បុគ្គលមានបុណ្យធ្វើហើយ ប្រាកដក្នុងទីគ្រប់អន្លើ ទោះបីក្នុងទីមិនមែនជាអាករដ្ឋានក៏ដោយ ។

បុគ្គលឥតលក្ខណ៍ គឺបុគ្គលឥតបុណ្យនេះ ទុកជាមានសិប្បៈក្តី ឥតសិប្បៈក្តី ស្ទុះស្ទាស្រវាស្រទេញ ប្រមុំប្រមូល សវិញ្ញាណកា–វិញ្ញាណកទ្រព្យទុកជាក់ច្រើនយ៉ាងណាក៏ដោយ សវិញ្ញាណកាវិញ្ញាណកទ្រព្យទាំងនោះ គង់តែវិនាសដោយចោរភ័យ គឺភ័យអំពីចោរលួចប្លន់ឆក់ដណ្តើមយកទៅក៏មាន ដោយអមនុស្សភ័យ គឺភ័យអំពីខ្មោចបិសាចរាជភូតធ្វើកលមាយាផ្សេងៗ ឬក៏អំពីទេព្តា យក្សជាដើម ដែលជាអ្នកឥតធម៌សប្បុរស ធ្វើទុក្ខបុកម្នេញឲ្យវិនាសទៅក៏មាន ដោយអគ្គិភ័យ គឺភ័យអំពីភ្លើងឆេះឆាបដល់ទ្រព្យមានវិញ្ញាណ និងទ្រព្យឥតវិញ្ញាណទាំងនោះឲ្យខូចខាតអន្តរាយ គ្មានស្រាកស្រាន្ត មុខណាមួយក៏មាន ដោយឧទកភ័យ គឺភ័យអំពីទឹកជន់ ជំនន់លិចទ្រព្យទាំងអស់នោះ ព្រមទាំងខ្លួនក៏មាន ពុំនោះសោតទេ កណ្តៀរ, កណ្តុរកាត់ ឬស្រាប់តែពុកផុយរលួយឯងៗទៅក៏មាន,(១) ទ្រព្យឯណាដែលមិនមាន ក៏មិនកើតមានតែងវិនាសទៅ រកបរិភោគប្រើប្រាស់មិនកើតឡើយ សេចក្តីអន្តរាយដែលរៀបរាប់ដោយខ្លីមកនេះ ក៏មកតែអំពីមិនមានសរិគឹបុណ្យកុសលដែលជាកំណប់ទ្រព្យ ។

ឯមនុស្សអ្នកមានបុណ្យវិញ ភោគទ្រព្យសព្វបែបមិនកន្លងនូវគេទេ តែងកើតឡើងដល់មនុស្សអ្នកមានបុណ្យនោះសព្វទីកន្លែង ត្រៀងឧប–

(១) ដោយរាជភ័យ គឺភ័យអំពីសេចក្តីរឹបជាន់ដោយហេតុផ្សេងៗ ក៏មាន

កាគត្រៀងបរិភោគទឹងហានន្តរស័ក្តិ ជានាហ៊ានមុខមន្ត្រីជាដើម ដែលសត្វលោកនិយមត្រូវការ រមែងកើតមានសម្បូណ៌តាមតែគេត្រូវការ ឬប្រាថ្នាយ៉ាងណា បានយ៉ាងនោះ, សូម្បីកន្លែងណា ដែលមិនទំនងកកើតនូវភោគៈទាំងឡាយ ក៏គង់ដុះកើតឡើងបាន តែបើអ្នកមានបុណ្យ នៅស្ម័គ្រស្នាគមជាមួយហើយ ក្នុងទីកន្លែងនោះៗ គេតែងបានសុខកាយសប្បាយចិត្តនេះមកតែអំពីអ្នកមានបុណ្យព្រេងគឺសិរីដែលជាគំនូរបុណ្យនេះឯង ។

ចប់សិរីតែប៉ុណ្ណេះ

---

## អធិប្បាយអំពីតណ្ហា

## ធម៌ទី ៣

ពាក្យថាឥច្ឆា ប្រែថាសេចក្ដីប្រាថ្នានេះ បើប្រែតាមអត្ថរបស់បទដទៃ ៗ ឃើញថាមានសព្ទប្រែគួររួមចូលក្នុងពាក្យថាប្រាថ្នាដែរ ប៉ុន្តែប្លែកគ្នាដោយរូបសព្ទយ៉ាងនេះ ឥច្ឆា ប្រែថាសេចក្ដីប្រាថ្នា, តណ្ហា ប្រែថាចំណង់ បត្ថនា ប្រែថាការតាំងចិត្ត, ការផ្គួងចិត្ត, កាម ប្រែថា សេចក្ដីត្រូវការឬចំណង់, ឆន្ទ ប្រែថាការពេញចិត្ត; ពាក្យប្រែរបស់សព្ទទាំងប៉ុន្មាន ដែលពោលដោយសង្ខេបខាងលើនេះ ជាឈ្មោះនៃដំណើរខាងផ្លូវចិត្តទាំងអស់ គឺជាផ្នែកនៃការប្រព្រឹត្តរបស់ចិត្ត ។

គឺឯសេចក្តីប្រាថ្នា ដែលទេព្តាទូលសួរព្រះអង្គ ហើយព្រះអង្គដោះប្រស្នានោះថា សេចក្តីប្រាថ្នារមែងកើតកន្ត្រាក់នរជនយកទៅ សេចក្តីប្រាថ្នានោះកម្របុគ្គលលះបានក្នុងលោក , សត្វមានកិលេសក្រាស់រមែងជាប់ជំពាក់នៅក្នុងសេចក្តីប្រាថ្នា ពាក្យទាំង ៣ ម៉ាត់នេះ រួមទៅលើតែពាក្យ ១ ម៉ាត់ គឺសេចក្តីប្រាថ្នា ; សេចក្តីប្រាថ្នានេះហើយតែងដឹកនាំនរជនទៅ-កាន់ភពតូច-ធំ, ម្តងកើតកន្ត្រាក់ទៅកាន់ទីទាប ម្តងកើតកន្ទ្រាក់ទៅកាន់ទីខ្ពស់ រាប់ជាតិកំណើតមិនបាន ព្រោះតែឥច្ឆា គឺសេចក្តីប្រាថ្នា ។

